## ក្របខ័ណ្ឌគតិយុត្តដែលពាក់ព័ន្ធការងារគ្រប់គ្រង និងដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត

១. ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦
២. ច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៤
៣. ច្បាប់ភូមិបាល ឆ្នាំ២០០១
៤. ច្បាប់ស្ដីពីសម្បទាន ឆ្នាំ២០០៧
៥. អនុក្រឹត្យស្ដីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្នាំ១៩៩៩
៦. អនុក្រឹត្យស្ដីពីដីសម្បទានសង្គម ឆ្នាំ២០០៣
៧. អនុក្រឹត្យស្ដីពីដីសម្បទានសេដ្ឋកិច្ច ឆ្នាំ២០០៥
៨. អនុក្រឹត្យស្ដីពីការគ្រប់គ្រងអាងទន្លេ ឆ្នាំ២០១៥
៩. អនុក្រឹត្យលេខ១៩៧ អនក្រ.បក ស្ដីពីការគ្រប់គ្រងដីចំណីតាមបណ្ដាញផ្លូវជាតិ និងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
១០. សេចក្ដីប្រកាសលេខ០៦ ស្ដីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី ឆ្នាំ១៩៩៩
១១. សារាចរលេខ ០២ ស្ដីពីការកាន់កាប់ដីរបស់រដ្ឋខុសច្បាប់ ឆ្នាំ២០០៧
១២. សារាចរលេខ ០៣ ស្ដីពីដំណោះស្រាយលំនៅដ្ឋានបណ្ដោះអាសន្ននៅលើដីរបស់រដ្ឋដែលកាន់កាប់នៅរាជធានី និងតំបន់ទីក្រុង ឆ្នាំ២០១០
១៣. ប្រកាសលេខ ០៦ ស្ដីពី"វិធានការបង្ក្រាបការរំលោភ និងការទន្ទ្រានយកដីដោយអនាធិបតេយ្យ" ឆ្នាំ២០១០
១៤. សារាចរលេខ ០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីនីតិវិធីអនុវត្តការតាំងទីលំនៅឡើងវិញសម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំ២០១៤
១៥. លិខិតលេខ៩៦១ សហវ ស្ដីពីការអនុវត្តន៍គោលនយោបាយដីចំណីផ្លូវចំពោះផ្លូវជាតិ ផ្លូវខេត្ត ផ្លូវឃុំ និងផ្លូវរថភ្លើង ឆ្នាំ២០០៩
១៦. ប្រកាសស្ដីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ឆ្នាំ២០០៩

## គោលការណ៍អន្តរជាតិស្ដីអំពីការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត

ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank)
ធនាគារពិភពលោក (World Bank)
សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (International Financial Corporation)



## បទពិសោធន៍ល្អ អំពីការងារដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តសម្រាប់គម្រោងអភិវឌ្ឍន៍ឯកជន




## ជម្រើសសំណង




- ផ្ដល់នូវជម្រើសរួមបញ្ចូលគ្នាទាំងដី ឬទ្រព្យសម្បត្តិ និងប្រាក់ ដោយផ្អែកលើកិច្ចព្រមព្រៀងជាមួយក្រុមគ្រួសារដែលទទួលរងផលប៉ះពាល់
- ផ្ដល់នូវសំណងជំនួសសមរម្យដូចជាដី ឬទ្រព្យសម្បត្តិផ្សេងៗសម្រាប់ដី និងទ្រព្យសម្បត្តិដែលខូចខាត ឬដែលត្រូវដកហូត
- ផ្ដល់ប្រាក់គ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យបុគ្គល ឬក្រុមគ្រួសារដែលទទួលរងផលប៉ះពាល់អាចទទួល ឬទិញដី ឬទ្រព្យសម្បត្តិដែលមានតម្លៃស្មើ ឬដែលមានផលិតភាពល្អប្រសើរជាងមុននៅក្នុងតំបន់ស្រដៀងគ្នាទៅតាមតម្លៃទីផ្សារបច្ចុប្បន្ន នៅពេលធ្វើលទ្ធកម្មដី ឬនៅពេលទូទាត់ចំណាយ (តម្លៃជំនួស)



ក្រាហ្វិកទី 13៖ គំរូអនុវត្តរូបមន្តស្បែកខ្លា




## បញ្ហាសំខាន់ៗមួយចំនួន...






ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បរិស្ថាន

ក្រសួងបរិស្ថាន

# សៀវភៅណែនាំស្ដីពីការងារដោះស្រាយផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តសម្រាប់គម្រោងអភិវឌ្ឍន៍ឯកជន

## គោលបំណង

- រៀបរាប់អំពីបទបញ្ញត្តិ និងដំណើរការនានាដែលមានសុពលភាពក្នុងការអនុវត្តកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងក្នុងការជួយដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងវិនិយោគឯកជន
- លើកឡើងអំពីស្ថាប័នទទួលខុសត្រូវ និងយន្តការចាំបាច់សម្រាប់ការងារដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងវិនិយោគឯកជន
- បង្ហាញជូននូវបទពិសោធន៍ជាក់ស្ដែងដែលបានអនុវត្តន៍កន្លងមកជាមួយការងារដោះស្រាយផលប៉ះពាល់ពីគម្រោងវិនិយោគឯកជន
- ផ្ដល់ជូននូវអនុសាសន៍សំខាន់ៗ ដែលគួរពិចារណាក្នុងការរៀបចំការងារដោះស្រាយផលប៉ះពាល់ និងសម្រាប់រៀបចំព័ត៌មានបន្ថែមនៅក្នុងរបាយការណ៍។



រៀបចំដោយ
នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

គាំទ្រដោយ
AFSC

## កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
## (ផ្អែកលើការប្រតិបត្តិជាក់ស្តែង)

❶ **ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សារៀបចំសំណើដាក់ជូនក្រសួងបរិស្ថាន** (នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន - EIA)

❷ **ធ្វើចំណាត់ថ្នាក់គម្រោង**
(នាយកដ្ឋាន EIA)

របាយការណ៍ EIA (ពេញលេញ) | របាយការណ៍ IEIA (ដំបូង) | កិច្ចសន្យាការពារបរិស្ថាន

**លក្ខខណ្ឌការងារ**
(នាយកដ្ឋាន EIA កំណត់ទំហំ និងពិនិត្យលើវិធីសាស្ត្រ)

❸ **រៀបចំរបាយការណ៍** EIA **និង**IEIA ដាក់ជូនក្រសួងបរិស្ថាន
ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា

❹ **ចុះត្រួតពិនិត្យទីតាំង** និង ❺ **ប្រជុំផ្តល់យោបល់បច្ចេកទេស**
លើរបាយការណ៍ EIA និងIEIA
(ក្រុមការងារនាយកដ្ឋាន EIA)

❻ **កិច្ចប្រជុំអន្តរក្រសួង** (ជាមួយសង្គមស៊ីវិល) ផ្តល់យោបល់
ទៅលើរបាយការណ៍ EIA និងIEIA

តម្រូវឱ្យ **កែសម្រួល** របាយការណ៍ឡើងវិញ | **ឯកភាព** លើរបាយការណ៍ → **តាមដានការអនុវត្ត** ផែនការគ្រប់គ្រងបរិស្ថាន

**ការចូលរួមពីសាធារណជន**

**ការចូលរួមពីសាធារណជនក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម** គឺជាការចូលរួមពិគ្រោះយោបល់របស់អ្នកពាក់ព័ន្ធជាមួយគម្រោងអភិវឌ្ឍន៍ រួមមាន ក្រសួង/ស្ថាប័ន អាជ្ញាធរមូលដ្ឋាន មន្ទីរពាក់ព័ន្ធ ម្ចាស់គម្រោង ក្រុមហ៊ុនទីប្រឹក្សា តំណាងប្រជាពលរដ្ឋរងផលប៉ះពាល់ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការពាក់ព័ន្ធតំបន់គម្រោង។

គោលបំណងនៃការចូលរួមពីសាធារណជន និងស្ថាប័នពាក់ព័ន្ធនេះ គឺដើម្បីបង្ហាញពីព័ត៌មានលម្អិតរបស់គម្រោង ក៏ដូចជាការទទួលយកនូវការព្រួយបារម្ភ មតិរិះគន់ កែលម្អ យោបល់គាំទ្រ និងព័ត៌មានលម្អិតពាក់ព័ន្ធនឹងបរិស្ថានដែលមានស្រាប់ក្នុងតំបន់គម្រោង។



សកម្មភាពចុះប្រមូលព័ត៌មាន ទិន្នន័យ
និងពិភាក្សាជាមួយភាគីពាក់ព័ន្ធនៅក្នុងតំបន់មូលដ្ឋាន



ក្រុមការងាររបស់ក្រសួងបរិស្ថានចុះសិក្សា និងត្រួតពិនិត្យគម្រោង



កិច្ចប្រជុំថ្នាក់នាយកដ្ឋាន
វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

កិច្ចប្រជុំអន្តរក្រសួងត្រួតពិនិត្យ
លើរបាយការណ៍



## ស្ថានភាពនៃការអភិវឌ្ឍ និងហេតុប៉ះពាល់សំខាន់ៗ






## បញ្ហាប្រឈមនិងវិធីសាស្ត្រក្នុងការដោះស្រាយលើការរុះរើលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត

**ផលប៉ះពាល់ទៅលើការរុះរើលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត** គឺសំដៅទៅលើឥទ្ធិពលអាក្រក់ ឬផលប៉ះពាល់អវិជ្ជមានពីគម្រោងអភិវឌ្ឍន៍ ឬគម្រោងវិនិយោគនានាទៅលើការតាំងទីលំនៅដោយតម្រូវឱ្យមានការផ្លាស់ប្តូរទីលំនៅជារូបវន្តរបស់ប្រជាជនដោយមិនស្ម័គ្រចិត្តដែលត្រូវចាកចេញពីផ្ទះសម្បែង អាជីវកម្មរបស់ខ្លួន និងឬការកាន់កាប់ទ្រព្យសម្បត្តិទាំងឡាយ មុនពេលគម្រោងត្រូវបានអនុវត្តន៍។ ផលប៉ះពាល់នេះផ្តោតទៅលើការខាតបង់ដោយផ្ទាល់ និងប្រយោលផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលប្រជាជនធ្លាប់ទទួលផល និងប្រតិបត្តិដោយស្របច្បាប់។

**នរណាជាអ្នកទទួលរងផលប៉ះពាល់ទៅលើការរុះរើលំនៅដោយមិនស្ម័គ្រចិត្ត៖**
ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ គឺសំដៅលើអ្នកទាំងឡាយណាដែលត្រូវបានជម្លៀសដូចជា ការផ្លាស់ប្តូរទីលំនៅ ការបាត់បង់ដីលំនៅដ្ឋាន ឬការបាត់បង់ទីជម្រក និងការប៉ះពាល់ផ្នែកសេដ្ឋកិច្ចដូចជា ការបាត់បង់ដីធ្លី ទ្រព្យសម្បត្តិ ប្រភពចំណូល ឬក៏ជីវភាពរស់នៅដែលជាលទ្ធផលបណ្តាលមកពី (ក) ការទន្ទ្រានយកដីធ្លីដោយមិនស្ម័គ្រចិត្ត ឬ (ខ) ការហាមឃាត់លើការប្រើប្រាស់ដីដោយមិនស្ម័គ្រចិត្ត ឬទៅលើការចូលទៅកាន់តំបន់ឧទ្យានដែលបានកំណត់ ឬតំបន់ការពារស្របច្បាប់។ ក្នុងករណីនេះ លំនៅដ្ឋានដែលទទួលរងផលប៉ះពាល់ ត្រូវរួមបញ្ចូលសមាជិកទាំងអស់ដែលរស់នៅក្រោមដំបូលផ្ទះតែមួយ ហើយប្រកបរបរចិញ្ចឹមជីវិតតែមួយមុខដែលទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមានដោយគម្រោង ឬផ្នែកណាមួយរបស់គម្រោង។

## នីតិវិធីសង្ខេបក្នុងការដោះស្រាយបណ្តឹងតវ៉ាអំពីផលប៉ះពាល់លើការតាំងទីលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តសម្រាប់គម្រោងអភិវឌ្ឍន៍ឯកជន

**ដំណាក់កាលទី១**
ដាក់ពាក្យតវ៉ា ឬបណ្តឹងដោយផ្ទាល់មាត់ ឬការសរសេរជាលាយល័ក្ខណ៍អក្សរ
↓
*ផ្ញើទៅមេភូមិ មេឃុំ-ចៅសង្កាត់ត្រូវធ្វើការសម្របសម្រួល និងដោះស្រាយបណ្តឹងតវ៉ានានា*
១៥ថ្ងៃ

**ដំណាក់កាលទី២**
ការិយាល័យស្រុក/ខណ្ឌដោះស្រាយពាក្យបណ្តឹងតវ៉ាដើម្បីឱ្យមានការពេញចិត្តដល់ភាគីពាក់ព័ន្ធទាំងអស់
↓
*ការិយាល័យស្រុក/ខណ្ឌនឹងបញ្ជូនករណីនេះទៅកាន់អាជ្ញាធរថ្នាក់ខេត្តដើម្បីធ្វើការដោះស្រាយបន្ត*
១៥ថ្ងៃ

**ដំណាក់កាលទី៣**
អាជ្ញាធរថ្នាក់ខេត្តនឹងជួបជាមួយភាគីពាក់ព័ន្ធ និងព្យាយាមដោះស្រាយបណ្តឹងតវ៉ានានាដែលនៅសេសសល់
↓
*អាជ្ញាធរថ្នាក់ខេត្តនេះត្រូវតែធ្វើការសម្រេចចិត្តជាលាយលក្ខណ៍អក្សរអំពីដំណោះស្រាយណាមួយ*
៣០ថ្ងៃ

**ដំណាក់កាលទី៤**
អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីនឹងសិក្សានិងពិភាក្សាសំណុំរឿងទំនាស់របស់ភាគីពាក់ព័ន្ធទាំងអស់
↓
*អាជ្ញាធរជាតិនេះនឹងធ្វើសេចក្តីសម្រេចចិត្តជាលាយលក្ខណ៍អក្សរអំពីដំណោះស្រាយណាមួយ*

***ដំណាក់កាលដោះស្រាយក្រៅប្រព័ន្ធតុលាការ***

**ដំណាក់កាលចុងក្រោយ**
***(តាមប្រព័ន្ធតុលាការ)***
↓
**សាលាដំបូងរាជធានី-ខេត្ត/សាលាឧទ្ធរណ៍តំបន់ និងតុលាការកំពូល**